**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

<u>តុលាការកំពូល</u>

សំណុំរឿងរដ្ឋប្បវេណី

លេខ ១៧

ចុះថ្ងៃទី ១៩-០១-២០០០

សាលដីកា

លេខ ១៤៧

ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០០

តាងនាមប្រជារាស្ត្រខ្មែរ

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០០០ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម | ឌិត មុន្ទី | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២- | លោក | ប៉ែន ស៊ុន | ចៅក្រម |
| ៣- | លោក | វឿល មួន | ចៅក្រម |
| ៤- | លោក | ស៊ិន ឌឹម | ចៅក្រម |
| ៥- | លោក | ជីវ កេង | ចៅក្រម |
| ៦- | លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៧- | លោក | ប្រាក់ គីមសាន | ចៅក្រម |
| ៨- | លោក | សោម សិរីវឌ្ឍ | ចៅក្រម |
| ៩- | លោក | យស់ សូខឿន | ចៅក្រម |

ក្រឡាបញ្ជី

កញ្ញាហុក សុខធុល

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ១៤ក ចុះថ្ងៃទី១៣-០១-២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦៣ ចុះថ្ងៃទី១៧-១១-១៩៩៩ របស់សាលាឧទ្ធរណ៍ រវាង :

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ គ្រួច គីរី ភេទប្រុស ជាតិខ្មែរ របររកស៊ី ប្រធានកងជីវពល មានទីលំនៅសព្វថ្ងៃនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលក្រសួងកសិកម្ម ។ ឳពុកឈ្មោះ គ្រួច បានយូ ស្លាប់ ម្តាយឈ្មោះ បាន យិន ស្លាប់ ប្រពន្ធឈ្មោះ ស៊ុំ សុខា ។

មានលោកសោម ចន្ទឌីណា មេធាវី

និងចុងបណ្តឹងសាទុក្ខឈ្មោះ លឹម ឡាន ភេទស្រី អាយុ៩០ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់បាយ និង គុយទាវ ទីលំនៅសព្វថ្ងៃផ្ទះលេខ ៥៤ E1 ផ្លូវ ២៧១ សង្កាត់អូរឫស្សីទី ៤ ខណ្ឌ៧មករា ក្រុងភ្នំពេញ ។

មេធាវី លោក សេងរិន

<u>កម្មវត្ថុបណ្ដឹង</u> :ប្ដឹងសុំជួលអាហារដ្ឋាន និង ដាក់អោយដេញថ្លៃ

បានឃើញបណ្ដឹងសាទុក្ខលេខ២៤ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០០០ របស់លោកគ្រូច គីរី ប្ដឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ១៤ ( ក ) ចុះថ្ងៃទី១៣-០១-២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១៧ ចុះថ្ងៃទី១៩-០១-២០០០ របស់តុលាការកំពូល ។

តាមបណ្ដឹងចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៩៧ របស់ដើមចោទឈ្មោះ លឹម ឡាន ថា : ខ្លួនប្ដឹងសុំជួលអាហារដ្ឋាន សេ លីប បន្ត រឺដាក់ដេញថ្លៃជាសាធារណៈ ដោយហេតុថា ខ្លួនបានជួលអាហារដ្ឋាននេះ ពីនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលនៃក្រសួងកសិកម្មកាលពីឆ្នាំ១៩៨៨ រហូតមកដល់សព្វថ្ងៃ ហើយខ្លួនបានសាងសង់អាហារដ្ឋានសេលីបនេះ តាមលក្ខន្តិកៈសហជីប ចុះថ្ងៃទី ២៦-១០-៨៨ នៅឆ្នាំ១៩៩២ ខ្លួន និង នាយដ្ឋានបសុព្យាបាលបានធ្វើកិច្ចសន្យាចុះថ្ងៃទី ០១-ធ្នូ-១៩៩២ កែប្រែតំលៃជួលឡើងដល់ 200$US ក្នុង០១ខែ ដោយរក្សាទុកនូវមាត្រាទាំងអស់ ដែលមានចែងក្នុងលក្ខន្តិកៈជួលនៅឆ្នាំ១៩៨៨ អោយនៅដដែល បានន័យ ថា បន្តជួលឱ្យខ្លួន ០៥ឆ្នាំតទៅទៀត ។

នៅថ្ងៃទី០៥-៨-៩៦ ខ្លួនបានដាក់ពាក្យសុំជួលបន្តនូវដីអាហារដ្ឋាននោះ ក្នុងរយៈពេល៤០ឆ្នាំ តាមមាត្រា ៦ នៃលក្ខន្តិកៈរួចហើយ ប៉ុន្តែនៅថ្ងៃទី ២៨-០១-៩៧ រដ្ឋមន្ត្រីក្រសួងកសិកម្ម បានចេញលិខិតលេខ ៤២៨ កសក. បានសំរេចជួលទីតាំងអាហារដ្ឋាននោះឱ្យទៅឈ្មោះ សុខ ជា ទៅវិញដោយពុំបានឱ្យខ្លួនដឹង ហើយកិច្ចសន្យានោះទៀតសោតពុំទាន់ផុតកំណត់ជួលនៅឡើយ ។ ម្យ៉ាងទៀតពាក្យសុំជួលអាហារដ្ឋានរបស់ខ្លួនគឺហានឱ្យថ្លៃ00$US ដូចឈ្មោះ សុខ ជា ដែរហេតុអ្វីបានជាមិនជួលបន្តឱ្យខ្លួនបែរជាសំរេចជួលឱ្យគេផ្សេងទៅវិញ ។ខ្លួនជាអ្នកសាងសង់អាហារដ្ឋាននោះយ៉ាងលំបាក ហើយតស៊ូក្នុងការលក់ដូរតាំងពីពុំទាន់មានភ្ញៀវរហូតមកដល់សព្វថ្ងៃ មានភ្ញៀវដ៏ច្រើនដោយប្រើរយៈពេល ០៩ឆ្នាំ មកហើយហេតុអ្វីពុំផ្ដល់អាទិភាពឱ្យខ្លួនជួលបន្ត ។ ខ្លួនសំណូមពរសុំជួលអាហារដ្ឋាននេះបន្តដូចតម្លៃក្រសួងកសិកម្មសំរេចជួលឱ្យទៅឈ្មោះ សុខ ជា និង សុំទាមទារជំងឺចិត្តដោយសារការបញ្ឈប់អាជីវកម្មរបស់ខ្លួន មុនពេលផុតកិច្ចសន្យាជួល និង ប្រាក់ថ្លៃចំណូលដែលបង់ខាត ។

តាមពាក្យបណ្ដឹងតបចុះថ្ងៃទី ០៨-១០-៩៧ របស់នាយកដ្ឋានបសុព្យាបាល និង ផលិតកម្មនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ បានប្ដឹងសុំរំលាយលក្ខន្តិកៈចុះថ្ងៃទី ២៦-១០-៨៨ របស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាលជាមួយនិងលោកទៀង សួរ អ្នកស្រី លឹម ឡាន និង អ្នកស្រី វ៉ាន់ វុឌ្ឍី ទុកជាមោឃៈ ដោយហេតុថា លក្ខន្តិកៈចុះថ្ងៃទី ២៦-៦-៨៨ បានកំណត់រយៈពេលជួលតែ ០៥ឆ្នាំទេ តាមមាត្រា៧នៃលក្ខន្តិកៈលុះដល់ពេលកំណត់ សាមីអាហារដ្ឋានសេលីប មិនព្រមគោរពតាមកិច្ចសន្យាឡើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៤០" ក " ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ ១៩៩៧ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

1- ទទួលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ លឹម ឡាន ចុះថ្ងៃទី ០៣-៦-៩៧ មានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយខុសនិងគតិច្បាប់.

២- ទទួលពាក្យបណ្តឹងរបស់ចុងចំលើយនាយកដ្ឋានផលិតកម្មបសុព្យាបាលក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- ទទួលលិខិតផ្ទេរសិទ្ធិរបស់ឈ្មោះ លឹម ឡាន ចុះថ្ងៃទី ៤-៦-៩៧ ឱ្យមេធាវី ឈ្មោះខូវ ចន្ថា ជាតំណាងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៤- ទទួលលិខិតប្រគល់សិទ្ធិរបស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ក្រសួងកសិកម្ម ឱ្យឈ្មោះហ៊ួត សម្បត្តិ , ប៊ូ - ធឿន និង គ្រួច គីរី ចុះថ្ងៃទី ៨-៩-៩៧ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៥- ទទួលលិខិតសុំពឹងពាក់មេធាវី ឈ្មោះ សោម ច័ន្ទឌីណា របស់នាយកដ្ឋានបសុព្យាបាលចុះថ្ងៃទី ២៩-៩-៩៧ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៦- រំលាយលក្ខន្តិកៈសហជីព ស្តីពីការបើក និង ដំណើរការអាហារដ្ឋានលេខ ៥០-៦៦៥-សជមជប ចុះថ្ងៃទី ២៦-១០-១៩៨៨ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមមាត្រា១០៧ នៃក្រិត្យច្បាប់លេខ៣៨ ចុះថ្ងៃទី ២៨-១០-១៩៨៨ ។

៧- បង្គាប់ឱ្យឈ្មោះ លឹម ឡាន ម្ចាស់អាហារដ្ឋានសេលីប តំណាងដោយមេធាវី ខូវ ចន្ថា ប្រគល់ទីតាំងដីឡូតិ៍លេខ ៤០ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខ័ណ្ឌដូនពេញរាជធានីភ្នំពេញ និង រុះរើសំណង់ចេញពីដីឡូតិ៍ ខាងលើ ឱ្យទៅនាយក- ដ្ឋានផលិតកម្ម និង បសុព្យាបាល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ តំណាង ដោយឈ្មោះ ហ៊ួត សម្បត្តិ , ប៊ូ ធឿន និង គ្រួច គីរី ចាប់ពីថ្ងៃប្រកាសសាលក្រមនេះចូលជាស្ថាពរ ។

៨- រឹបអូសប្រាក់ប្រដាប់ក្តី ៧០០០៛ ដែលឈ្មោះ លឹម ឡាន បានបង់ទុករួចជាស្រេចដើម្បីបង់ពន្ធហ្វ៊ីងនិង ពន្ធចុះបញ្ជីក្តី ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០៛ ។

៩- បង្គាប់ឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តី ៧០០០៛ គឺពន្ធចុះបញ្ជីក្តីនិង ពន្ធហ្វ៊ីង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០៛ ដែលចុងចំលើយបានបង់ទុករួចជាស្រេច ។

កាលបើហួសកំណត់ឧទ្ធរណ៍ហើយ បង្គាប់ឱ្យដើមចោទសងប្រាក់ ៧០០០៛ ទៅចុងចម្លើយវិញ ។

១០-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូភាគី សំរេចបើកផ្លូវឧទ្ធរណ៍ តាមកំណត់ច្បាប់ចាប់ពីថ្ងៃប្រកាសសាលក្រមតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៧៥ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧ របស់លោក លឹម ឡាន ប្តឹងមិនសុខចិត្ត និង សាលក្រមរដ្ឋប្បវេណីលេខ ១៤០ " ក " ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៧ របស់ តុលាការក្រុងភ្នំពេញលើ សេចក្តីសំរេចទាំមូល ។

បានឃើញសាលដីកាលេខ១៩៣ ចុះថ្ងៃទី ៣០ ខែមិនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍សំរេចចំ ពោះមុខចុងបណ្តឹងឧទ្ធរណ៍ និង មេធាវី កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ និង មេធាវី ដែលមានខ្លឹមសារនៃសេចក្តី សំរេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី លឹម ឡាន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធទីចោលដោយទាស់ និង គតិច្បាប់ ។

២- ទទួលស្គាល់ការផ្ទេរសិទ្ធិចុះថ្ងៃទី២២-០២-១៩៩៩ ពីអ្នកស្រី លឹម ឡាន ទៅមេធាវី ឈ្មោះ សេង រ៉ុន ទុកជាត្រឹមត្រូវតាមច្បាប់ ។

៣- បដិសេធនីបណ្តឹងសុំពន្យាពេលរបស់លោកមេធាវី សេង រ៉ុន ចោលជាអសារបង់ ។

៤- ដកល់សាលក្រមរដ្ឋប្បវេណីលេខ១៤០ " ក " ចុះថ្ងៃទី២៩-១០-១៩៩៧ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការពេញទាំងមូល ។

៥- រឹបអូសប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ដែលអ្នកស្រី លឹម ឡាន បានបង់រួចហើយគឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្វឹង ២៩៥០៛ រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់៤៥០៛ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥០០០៛ និង ចំណាយលើអាជ្ញាធរតុលាការ ៥០០០៛ សរុប ១៣.០០០៛ ។

6- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈនាពេលសវនាការចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ និង មេធាវី កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ និង បើកផ្លូវប្តឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ២២ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ១៩៩៩ របស់អ្នកស្រី លឹម ឡាន ប្តឹងមិនសុខចិត្តនិងសាលដីកាលេខ១៥៣ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ២៨៤ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ សំរេចចំពោះ មុខ គ្រួច គីរី មេធាវី ចុងចំលើយ សោម ច័ន្ទឌីណា និង មេធាវី ដើមចោទ ជូ ច័ន្ទធារ៉ាកំបាំងមុខឈ្មោះ លឹម ឡាន ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងទាស់ចុះថ្ងៃទី២១-មេសា- ១៩៩៩ របស់ឈ្មោះលឹម ឡាន ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធនីសាលដីកាកំបាំងមុខលេខ១៥៣ ចុះថ្ងៃទី៣០-៣-៩៩ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

៣- បដិសេធនីលទ្ធផលដេញថ្លៃធ្វើឡើងដោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល មានបេក្ខជនឈ្មោះ លឹម ឡាន និង សុខ ជា កាលពីថ្ងៃទី ២៦-៩-៩៦ និង ២៩-១០-៩៦ ចោលជាអសារបង់ ។

៤- បដិសេធនីកិច្ចសន្យាជួលអាហារដ្ឋានរបស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ធ្វើឡើងរវាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ និង លោក សុខ ជា ចុះថ្ងៃទី០៣-មេសា- ១៩៩៧ ចោលជាអសារបង់ ។

៥- អនុញ្ញាតឱ្យ ដើមចោទ លឹម ឡាន បន្តធ្វើអាជីវកម្មលក់ដូរក្នុងរយៈពេល ២ឆ្នាំ ២៧ថ្ងៃ ដើម្បីបញ្ចប់កិច្ចសន្យាចាប់គិតពីថ្ងៃបន្តការលក់ដូរជាលើកទី២ ។

៦- បង្គាប់ឱ្យនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលក្រសួងកសិកម្មផ្តល់អាហារដ្ឋានសេលីប មកឱ្យដើមចោទឈ្មោះ-លឹម ឡាន ធ្វើអាជីវកម្មបន្តចាប់ពីសាលដីកាមានអានុភាពអនុវត្ត ។

៧- បង្គាប់ឱ្យនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលក្រសួងកសិកម្ម សងការខូចខាត ខកខាន មិនបានរកស៊ីចំនួន ៣០.០០០ដុល្លាអាមេរិកនិង ជំងឺចិត្តចំនួន ៥.០០០ ដុល្លាអាមេរិក ។

៨- សាលដីកានេះជំនុំជំរះចំពោះមុខ គ្រួច គីរី មេធាវី ចុងចំលើយ សោម ច័ន្ទឌីណា និង មេធាវី ដើមចោទ ជូ ច័ន្ទធារ៉ា កំបាំងមុខឈ្មោះ លឹម ឡាន ថ្ងៃទី៣១-៥-៩៩ និង ប្រកាសជាសាធារណៈថ្ងៃទី០៣-មិថុនា- ១៩៩៩ កំបាំងមុខគូក្តី តែចាត់ទុកជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១៧៤ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩៩ របស់លោក សោម ច័ន្ទឌីណា ជាមេធាវី ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ២៨៤ចុះថ្ងៃទី០៣ ខែ មិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៨៩ ចុះថ្ងៃទី២៨-១០-៩៩ របស់តុលាការកំពូលដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងសាទុក្ខលេខ ១៧៤ ចុះថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ១៩៩៩ របស់លោក សោម ច័ន្ទឌីណា មេធាវី ជំណាយឱ្យលោក គ្រួច គីរី ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ២៨៤ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៩៩ ចុះថ្ងៃ១៩ ខែកក្កដា ឆ្នាំ ១៩៩៩ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលចុងចំលើយបានបង់រួចហើយគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន ៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប ១៩.០០០៛ ហើយតម្រូវឱ្យអ្នកស្រី លឹម ឡាន សងប្រាក់ចំនួន ១៩.០០០៛ នេះទៅលោក គ្រួច គីរី វិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៩៩៩ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ០១ "ក" ចុះថ្ងៃទី០៦- ០១- ២០០០ របស់សាលាឧទ្ធរណ៍ បានជំនុំជំរះ សារឡើងវិញចំពោះមុខតំណាងនាយកដ្ឋានផលិតកម្មបសុព្យាបាល នៃក្រសួងកសិកម្ម កំបាំងមុខឈ្មោះ លឹម ឡាន ដែលមានខ្លឹម សារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលជំនុំជំរះជាសមត្ថកិច្ចដោយសាលដីការបស់តុលាការកំពូលបង្វិលសំណុំរឿងនេះមកអោយសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញតាមមាត្រា ១១នៃច្បាប់ស្តីពីការចាត់តាំងនិង សកម្មភាពសាលាជំរះក្តី ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៤០ "ក" ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៧ របស់តុលាការ ក្រុងភ្នំពេញទាំងមូល ។

៣- សំណូមពររបស់ចុងចំលើយសុំទាមទារសោហ៊ុយបង់ខាត និង ជំងឺចិត្តត្រូវលើកចោល ។

សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខតំណាងនាយកដ្ឋានផលិតកម្មបសុព្យាបាលនៃ ក្រសួងកសិកម្ម កំបាំងមុខឈ្មោះ លឹម ឡាន សំរេចបើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ០៥ ចុះថ្ងៃទី ១០-០១-២០០០ របស់អ្នកស្រី លឹម ឡាន ប្តឹងមិនសុខចិត្តសុខចិត្ត និង សាលដីការលេខ០១ ចុះថ្ងៃទី ៦-០១-២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៤ "ក" ចុះថ្ងៃទី១៣-០១-២០០០ របស់សាលាឧទ្ធរណ៍បានជំនុំជំរះសារឡើងវិញចំពោះមុខបណ្តឹងទាស់លោកគ្រួច គីរី កំបាំងមុខដើមបណ្តឹងទាស់អ្នកស្រី លឹម ឡាន តែចាត់ទុកជាចំពោះមុខដែលមានខ្លឹមសារនៃ សេចក្តីសំរេចដូចតទៅ :

១- សំរេចទទួលបណ្តឹងទាស់របស់លីម ឡាន ចុះថ្ងៃទី ១០-០១-២០០០ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២- សំរេចបដិសេធន៍សាលដីកាសាលាឧទ្ធរណ៍លេខ ០១ " ក " ចុះថ្ងៃទី ០៦-០១-២០០០ សំរេចកំបាំងមុខ ចោលជាអសារបង់ ហើយសំរេចជាថ្មីថា :

ក- សំរេចបដិសេធន៍លទ្ធផលដេញថ្លៃធ្វើឡើងដោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលមាន បេក្ខជនឈ្មោះ លីម ឡាន និង សុខ ជា កាលពីថ្ងៃទី ២៦-៩-១៩៩៩៦ និង ថ្ងៃទី២៩-១០-១៩៩៦ ចោលជាអសារបង់ ។

ខ- បដិសេធន៍កិច្ចសនាជួលអាហារដ្ឋានរបស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ធ្វើឡើងរវាង ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ និង លោក សុខ ជា ចុះថ្ងៃទី ០៣-៤-១៩៩៧ ចោលជាអាសារបង់ ។

គ- អនុញ្ញាតអោយ លីម ឡាន បន្តធ្វើអាជីវកម្មលក់ដូរក្នុងរយៈពេល ២ឆ្នាំ ២៧ថ្ងៃ ដើម្បីបញ្ចប់ កិច្ចសន្យាចាប់គិតពីថ្ងៃបន្តការលក់ដូរលើកទី ២ ។

ឃ- បង្គាប់អោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលក្រសួងកសិកម្មផ្តល់ អាហារដ្ឋាន សេលីប មកអោយដើមចោទ លីម ឡាន ធ្វើអាជីវកម្មបន្តចាប់ពីសាលដីកាមានអានុភាព អនុវត្ត ។

ង- បង្គាប់អោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ក្រសួងកសិកម្ម សងការខូចខាតខកខាន មិនបានរកស៊ីចំនួន ៣០.០០០ដុល្លាអាមេរិក (បីម៉ឺនដុល្លាអាមេរិក ) និងជំងឺចិត្ត ៥០០០ដុល្លា អាមេរិក ( ប្រាំពាន់ដុល្លាអាមេរិក ) ទៅអោយលីម ឡាន ។

ច- បដិសេធសំណូមពររបស់ចុងចំលើយលោក គ្រួច គីរី តំណាងនាយកដ្ឋានផលិតកម្មបសុព្យាបាល ក្រសួងកសិកម្ម និង នេសាទ សុំជំងឺចិត្ត និង សាហ៊ុយបង់ខាត ។

សាលដីការនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខចុងបណ្តឹងទាស់លោក គ្រួច គីរី តំណាងអោយនាយកដ្ឋាន ផលិតកម្ម បសុព្យាបាលនៃក្រសួងកសិកម្ម និង នេសាទ កំបាំងមុខដើមបណ្តឹងទាស់អ្នកស្រី លីម ឡាន តែចាត់ដូចជាចំពោះមុខ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៤ ចុះថ្ងៃទី ១៣-០១-២០០០ របស់លោកគ្រួច គីរី ប្តឹងមិនសុខចិត្ត នឹង សាលដីកាលេខ ១៤ " ក " ចុះថ្ងៃទី ១៣-០១-២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី២៤-01-2000 របស់លោក គ្រួច គីរី.

បានឃើញសារណាតបចុះថ្ងៃទី 29-02-2000 របស់អ្នកស្រី លីម ឡាន .

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការបស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈផ្ទុយ និង គតិច្បាប់ ។ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់

បានស្តាប់ចំលើយរបស់លោក គ្រួច គីរី ជាចុងចំលើយ និង ជាដើមបណ្តឹងសាទុក្ខបានឆ្លើយនាពេលសវនាការ សាលា ឧទ្ធរណ៍ពុំបានកាត់ក្តីដោយយុត្តិធម៌ ដោយព្រមតាមកិច្ចសន្យា លើកទីមួយទេ ការជួលលើកទី២ គ្មានសន្យាទេគ្រាន់តែយកឈ្នួលថ្មី

រយៈពេលមួយឆ្នាំ គឺបង់ ២០០ដុល្លា ដោយនាយកដ្ឋានមិនទាន់មាន គោលការណ៍ច្បាស់លាស់ គឺទុកពេល អោយអាហារដ្ឋានចេះតែលក់បន្ត ដោយពុំបានធ្វើកិច្ចសន្យាអ្វីទេ ។ខ្លួនសុំអោយអ្នកស្រី លឹម ឡាន ប្រគល់ដីឡូតិ៍នេះអោយក្រសួងវិញ ។

ក្រឡាបញ្ជីអានសារណាតបរបស់អ្នកស្រី លឹម ឡាន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី សោម ច័ន្ទឌីណា តំណាងអោយឈ្មោះ គ្រួច គីរី ជាដើមបណ្តឹងសាទុក្ខនៅពេលសវនាការថា : នាយកដ្ឋានបសុព្យាបាល បានជួលដីឡូតិ៍លេខ ៤០ អោយទៅឈ្មោះ ទេវុង សួន វ៉ាន់ វុឌ្ឍី និង លឹម ឡាន បើកអាហារដ្ឋាន ឈ្មោះសេ លីប ក្នុងរយៈពេល ៥ឆ្នាំ លុះផុតកំណត់ តំណាងអាហារដ្ឋានសុំជួលបន្ត តែសហជីពពុំព្រម ដោយហេតុថា ដីឡូតិ៍នេះ សហជីពបានប្រគល់ជូន នាយកដ្ឋាន និង ក្រសួងកសិកម្មទៅហើយ តែដោយនាយកដ្ឋានមិនទាន់មានគោលការច្បាស់លាស់ បានទុកពេលអោយអាហារដ្ឋានលក់បន្តជាបណ្តោះអាសន្ន ពុំមែនមានលក្ខខ័ណ្ឌថាជួលបន្តរឺ ជាប់កិច្ចសន្យាជាមួយតំណាងអាហារដ្ឋានក្នុងរយៈពេល ៥ឆ្នាំ នោះទេ ព្រោះក្នុងលិខិតមួយឆ្នាំចុងក្រោយមិនមានចែង ។ដល់ឆ្នាំ ១៩៩៦ ក្រសួងមានផែនការថ្មីដោយអោយធ្វើការដេញថ្លៃតាមនីតិវិធីកំណត់របស់នាយកដ្ឋាន ។

<u>សំណូមពរ</u>

-សុំតំកល់សាលក្រមលេខ ១៤០ " ក " ចុះថ្ងៃទី២៥ ខែ តុលា ឆ្នាំ ១៩៩៧ របស់តុលាការក្រុងភ្នំពេញទុកជាបានការពេញទាំងមូល ។

សុំតំកល់សាលដីការកំពង់មុខលេខ ១៥៣ ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ ១៩៩៩ របសឧទ្ធរណ៍ទុកជាបានការ ដដែល

សុំបដិសេធសាលដីកាលេខ ២៨៤ចុះថ្ងៃទី ០៣-០៦-៩៩ របស់សាលាឧទ្ធរណ៍

សុំប្រគល់ទីតាំងដីឡូតិ៍លេខ ៤០វិថីព្រះមុនីវង្សសង្កាត់ស្រះចក ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ មកនាយកដ្ឋានបសុព្យាបាល និង ផលិតកម្មវិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី សេង រ៉ុន តំណាងអោយអ្នកស្រី លឹម ឡាន ជាចុងបណ្តឹងសាទុក្ខនាពេលសវនាការថា មុននិងធ្វើសេចក្តីសន្និដ្ឋានខ្លួនសុំធ្វើការសោកស្តាយពីការ ដាក់ពាក្យពន្យាពេលសវនាការរបស់អ្នកស្រី លឹម ឡាន ដោយគាត់មានជំងឺនៅមន្ទីរពេទ្យ ។ហើយ និង សុំសួរថា តើលោកគ្រួច គីរី គាត់មានឋានៈជាអ្វីនៅក្នុងក្រសួង ក្នុងការធ្វើការប្តឹងនេះ ?

តុលាការកំពូលសំរេចបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍វិញដោយតុលាការកំពូលមានការភ័ន្តច្រឡំមិនអាចបកស្រាយអោយបានច្បាស់លាស់ នូវអ្វីទៅដែលហៅថាអត្ថិភាព ? នៅក្នុងការដេញថ្លៃតុលាការកំពូលថា នេះជានីតិវិធីរបស់ក្រសួងនោះជាការមិនត្រឹមត្រូវទេ ក្នុងការដេញថ្លៃចាំបាច់ត្រូវធ្វើក្នុងថ្ងៃជាមួយគ្នា ហើយត្រូវមើលលើច្បាប់ដេញថ្លៃរបស់ក្រសួងពាណិជ្ជ - កម្ម ។

ខ្លួនសូមធ្វើសេចក្តីសន្និដ្ឋានដូចក្នុងសារណារបស់កូនក្តីខ្លួន ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយរបស់តំណាងនាយកដ្ឋានផលិតកម្មបសុព្យាបាល សារណារបស់អ្នកស្រី លឹម ឡាន និង សេចក្តីសន្និដ្ឋានរបស់មេធាវី នៃគូភាគី
- ក្រោយពីពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២ លេខ ២៤ ចុះថ្ងៃទី ១៣-០១-២០០០ របស់លោក គ្រួច គីរី ប្តឹងពីសាលដីការដ្ឋប្បវេណីលេខ ១៤ "ក" ចុះថ្ងៃទី១៣-០១-២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះរួមក្រុមដល់អង្គសេចក្តីបាន តាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា២២៦ នៃច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីដែរ ។

យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ក្នុងការជំនុំជំរះជាថ្មីសំរេចអោយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាលនៃក្រសួងកសិកម្មជួលអាហារដ្ឋាន បន្តអោយអ្នកស្រី លឹម ឡាន ដោយសំអាងទៅលើសារណារបស់អ្នកស្រី លឹម ឡាន ទាំងស្រុង និង ពុំបានពិចារណាលើអង្គហេតុអោយបានត្រឹមត្រូវនោះ ជាការភ័ន្តច្រឡំ និង ជាការបំពានទៅ និង គោលការនៃការស៊ើបអង្កេត ។

យល់ឃើញថា ក្រោយពេលចប់កិច្ចសន្យាជួលលើកទី១ គូភាគីពុំបានធ្វើកិច្ចសន្យាណាមួយជាលាយលក្ខអក្សរទេ ដូច្នេះការជួលបន្តនេះជាការជួលបន្តដោយពុំមានកំណត់ថេរវេលា ដូចដែលកំណត់នៃមាត្រា ១០១ និង ១១០ នៃក្រិត្យច្បាប់លេខ ៣៨-ក្រ-ច ស្តីពីកិច្ចសន្យានិង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។ ហើយការដែលអ្នកស្រី លឹម ឡាន ដាក់ពាក្យសុំជួលអាហារដ្ឋានបន្តនៅឆ្នាំ ១៩៩៦ នោះបញ្ជាក់ថា អ្នកស្រីក៏ទទួលស្គាល់ដែរជាការជួលបន្ត របស់អ្នកស្រីពីមុនមកពុំមានកំណត់ថេរវេលាទេ ។

យល់ឃើញថា ការដែលមេធាវី ដើមចោទលើកឡើងថាកូនក្តីលោកមានសិទ្ធិជួលអាហារដ្ឋានបន្តតាមកំណត់ហេតុចុះថ្ងៃទី ២៦-១០-៩២ នោះ គឺជាការភ័ន្តច្រឡំពីព្រោះថា កំណត់ហេតុនេះគ្រាន់តែបញ្ជាក់លក្ខខ័ណ្ឌសំរាប់អនុវត្តឆ្នាំចុងក្រោយនៃកិច្ចសន្យាប៉ុណ្ណោះ សូម្បីតែអ្នកស្រី លឹម ឡាន ក៏បានដាក់ពាក្យសុំជួលអាហារដ្ឋាននោះបន្តចុះថ្ងៃទី ០៩-៨-៩៦ ទៀតដែរ ដែលបញ្ជាក់ថា អ្នកស្រី លឹម ឡាន ក៏បានដឹងច្បាស់ថាការជួលអាហារដ្ឋានបន្តក្នុងតំលៃ ២០០ដុល្លាអាមេរិកក្នុង ១ខែមិនមានរយៈពេល ៥ឆ្នាំទេ ។ម្យ៉ាងទៀតអ្នកស្រីក៏បា នចូលរួមដេញថ្លៃអាហារដ្ឋាននេះមុនការកំណត់ ៥ឆ្នាំ ដែរដូចមានកំណត់ហេតុចុះថ្ងៃទី២៦-៩-៩៦ស្រាប់ ។

យល់ឃើញថា មុននឹងមានវិធានការណ៍បិទទ្វារអាហារដ្ឋាននាយកដ្ឋានបសុព្យាបាល បានជូនដំណឹងអ្នកស្រី លឹម ឡាន រហូតដល់ ៣ លើកហើយនៅលើកទី ៣ អ្នកស្រីបានសុំពន្យាពេលបិទទ្វារនៅថ្ងៃទី ២៨-៤-៩៧ ដែលបញ្ជាក់ថា អ្នកស្រីបានយល់ព្រមបិទទ្វារអាហារដ្ឋាននេះហើយ ។

យល់ឃើញថា អ្នកស្រី លឹម ឡាន បានធ្វើសារណាការពារផលប្រយោជន៍របស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ហើយមេធាវី របស់អ្នកស្រី ក៏បនមកចូលរួមសវនាការនេះដែរ ប៉ុន្តែអ្នកស្រីពុំ បានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ១៤ "ក" ចុះថ្ងៃទី១៣-០១-២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខតំណាងនាយកដ្ឋានផលិតកម្មនិង បសុព្យាបាល កំបាំងមុខអ្នកស្រី លឹម ឡាន ប៉ុន្តែចាត់ទុកជាចំពោះមុខ :

១- ទទួលបណ្តឹងសាទុក្ខលេខ ២៤ ចុះថ្ងៃទី ១៣-០១-២០០០ របស់លោកគ្រួច គីរី ទុកជាត្រឹមត្រូវតាមទំរង់ នឹង គតិច្បាប់ ។

២_ ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ១៤ " ក " ចុះថ្ងៃទី ១៣_០១_២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣_ បង្គាប់ឱ្យអ្នកស្រី លឹម ឡាន ម្ចាស់អាហារដ្ឋាន សេ លីប ប្រគល់ទីតាំងដីឡូត៍លេខ ៤០ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ឱ្យទៅនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ និង ឱ្យរុះរើសំណង់ និង សំភារៈចេញពីដីឡូត៍ខាងលើនេះ ។

៤_ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលលោក គ្រួច គីរី បានបង់រួចហើយគឺ ៖

_ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹងចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

_ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតំរូវឱ្យអ្នកស្រី លឹម ឡាន សងប្រាក់ចំនួន ១៩.០០០៛ ទៅលោក គ្រួច គីរី វិញ ។

៥_ សាលដីកានេះជំនុំជំរះ នៅថ្ងៃទី ០៣ ខែសីហា ឆ្នាំ២០០០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០០ ។